# តួនាទីរបស់តុលាការ ក្នុងការការពារសិទ្ធិចម្បង (សិទ្ធិរួចផុតពីអំពើទារុណកម្ម)

ដោយ បណ្ឌិត មាស បូរ៉ា និង លោក នូ គឹមឈីវ

## ១. សេចក្តីផ្តើម

សន្ធិសញ្ញាអន្តរជាតិ ជាទូទៅត្រូវបានចុះហត្ថលេខាដោយរដ្ឋាភិបាល និងផ្តល់ការអនុញ្ញាតឲ្យចូលជាភាគីនៃសន្ធិសញ្ញា ដោយសភា។ សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ឬ ស្ថាប័នអន្តរជាតិ មិនអាចកំណត់នូវវិធីសាស្ត្រជាក់លាក់ និងបញ្ជាឲ្យរដ្ឋជាភាគី ប្រើប្រាស់នូវវិធីសាស្ត្រនោះ ដើម្បីអនុវត្តសន្ធិសញ្ញា ក្នុងស្រុកឲ្យមានប្រសិទ្ធភាពពេញលេញទេ។[1] ដូចនេះ វាអាស្រ័យទៅតាមបរិបទ និងយន្តការច្បាប់ ដែលប្រទេសនីមួយៗ បានប្រកាន់យក ដើម្បីអនុវត្តនូវសន្ធិសញ្ញា ដែលខ្លួនជាភាគី ដោយស្ម័គ្រចិត្ត និងសន្យាបំពេញតាមកាតព្វកិច្ចទាំងឡាយចែងក្នុងសន្ធិសញ្ញាទាំងនោះ។

មានឧបសគ្គជាច្រើន ដែលបានរាំងស្ទះដល់ការអនុវត្តសន្ធិសញ្ញាក្នុងស្រុក ឲ្យមានប្រសិទ្ធភាព ដូចជា ការអះអាងថា សន្ធិសញ្ញា ទាមទារឲ្យមាននូវបទប្បញ្ញត្តិច្បាប់ជាតិ អនុវត្តជាមុនសិន (Implementing Law)។[2] ឧទាហរណ៍ វាក្យខ័ណ្ឌទី១ មាត្រា ៤ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និង

[1] Johannes Van Aggelen, the Obligations Imposed by the International Covenants and Other Universal Human Rights Treaties, Including the Implementation by Domestic Courts, 2017, para.40, *see Ius Gentium.* Curitiba, vol. 8, n. 2, p. 333-361, jul./dez. 2017. Douglas Donoho, *Human Rights Enforcement in the Twenty-First Century*, 35 (1) Georgia Journal of International and Comparative Law, 2006, p. 12.

[2] មាត្រា ៤ នៃ អនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម បង្ហាញអំពី ការទាមទារឲ្យមានច្បាប់ ប្រសិនបើក្នុងករណី មិនទាន់មានដាក់អំពើទារុណកម្មជាបទឧក្រិដ្ឋ។ Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment, 10 December 1984, United Nations, Treaty Series, vol. 1465, p. 85 (មាត្រា ៤ នៃអនុសញ្ញាស្តីពីអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប បានចែងថា ១. រដ្ឋភាគី ត្រូវធានាថា ទារុណកម្មជាបទល្មើសក្រោមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន។ ច្បាប់នេះ ត្រូវអនុវត្តចំពោះការប៉ុនប៉ង ការ

ការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប ឆ្នាំ១៩៨៤ បានចែងថា៖ “*វដ្តភាគី ត្រូវធានាថា ទារុណកម្មជាបទល្មើសក្រោមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន*”។ ស្មារតីនៃមាត្រាខាងលើ បានន័យថា អំពើទារុណកម្ម អាចត្រូវបានចាត់ថា ជាបទឧក្រិដ្ឋបាន លុះត្រាតែអំពើទារុណកម្មនោះ ត្រូវបានបញ្ញត្តិក្នុងច្បាប់ជាមុនសិន។ ក្នុងករណីខ្លះ តុលាការ អាចអះអាងថា ខ្លួនមិនអាចប្រើសន្ធិសញ្ញានោះបានទេ ដោយសារសភា មិនទាន់ធ្វើច្បាប់ ធ្វើឲ្យសន្ធិសញ្ញា ជាផ្នែកមួយនៃប្រព័ន្ធច្បាប់ជាតិ។[3] ឥឡូវសូមសន្មត់ថា សភាបានធ្វើច្បាប់តម្រូវរួចហើយ ដូចនេះតុលាការអាចប្រើសន្ធិសញ្ញាបានហើយ។ អ្វីសំខាន់ គឺថា តើតុលាការពិចារណាប្រើក្នុងកម្រិតណា ហើយពិតជាផ្តល់ប្រសិទ្ធភាពពេញលេញដល់បទប្បញ្ញត្តិនៃសន្ធិសញ្ញាដែរឬទេ។ ក្នុងន័យនេះ តុលាការ គឺជាស្ថាប័នចុងក្រោយ ក្នុងការធ្វើឲ្យខ្លឹមសារនៃសន្ធិសញ្ញាសិទ្ធិមនុស្ស ត្រូវបានអនុវត្តយ៉ាងពិតប្រាកដ (Making Right into Reality)។ ប្រសិនបើមិនដូចនេះទេ សិទ្ធិមនុស្សមានតែនៅលើក្រដាស និងបបូរមាត់របស់មន្ត្រី ឬ អ្នកស្រាវជ្រាវតែប៉ុណ្ណោះ។

អត្ថបទនេះ មានបំណងបង្ហាញអំពី ការការពារសិទ្ធិជាក់ស្តែង តាមយន្តការតុលាការរបស់ប្រទេសមួយចំនួន ដោយផ្តោតលើសិទ្ធិចម្បងចំនួន ២ មានចែងក្នុងវដ្តធម្មនុញ្ញ គឺសិទ្ធិរស់រានមានជីវិត និងសិទ្ធិសុវត្ថិភាពបុគ្គល។ អត្ថបទនេះមាន បីផ្នែក ដោយរាប់បញ្ចូល ខ្លឹមសារមាត្រាពាក់ព័ន្ធ និងការអនុវត្ត រួមនឹងទ្រឹស្តី មុននឹងធ្វើការសង្ខេប ដែលជាផ្នែកចុងក្រោយ។

---

ប្រព្រឹត្តទារុណកម្ម ឬ អំពើប្រព្រឹត្តដោយជនណាម្នាក់ដែលចាត់ជាការសមគំនិត ឬ ការចូលរួមប្រព្រឹត្តទារុណកម្ម។ ២. វដ្តភាគីត្រូវផ្តន្ទាទោសចំពោះបទល្មើសទាំងនេះឱ្យបានសមស្រប តាមប្រភេទធ្ងន់ធ្ងរនៃបទល្មើសទាំងឡាយ)។

[3] នេះជាជំហររបស់ថៅក្រមប្រកាន់យកទ្រឹស្តី Dualism។

## ២. ខ្លឹមសារ

មុននឹងបរិយាយ ផ្នែកនេះ នឹងដកស្រង់នូវខ្លឹមសារមាត្រាមួយចំនួន ស្តីពីការហាមឃាត់អំពើទារុណកម្ម និងសិទ្ធិសុវត្ថិភាពបុគ្គល (Right to Personal Liberty) ព្រមទាំងបង្ហាញអំពីដំណាក់កាលណាដែល ជាការចោទប្រកាន់ថាមានការបំពានសិទ្ធិ ចូលក្នុងសមត្ថកិច្ចរបស់តុលាការ។

### ២.១. បទប្បញ្ញត្តិពាក់ព័ន្ធ

មាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦ បានបញ្ញត្តិថា៖ *"គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬការប្រព្រឹត្ត ឬទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬធ្វើឲ្យថោកទាបឡើយ។ ជាពិសេស ហាមឃាត់យកជនណាម្នាក់មកធ្វើពិសោធន៍ ខាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រមដោយសេរីពីសាមីខ្លួនឡើយ"*។ មាត្រា ៩ នៃកតិកាសញ្ញាដដែលបានចែងថា ៖ *"ជនគ្រប់រូប មានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់"*។[4]

### ២.២. សិទ្ធិចម្បង

មាត្រា ៣២ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា៖ *"ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន"* ។ មាត្រានេះ ស្របនឹងស្មារតីនៃមាត្រា ៣ នៃសេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស ឆ្នាំ១៩៤៨ របស់អង្គការសហប្រជាជាតិ។ សិទ្ធិ និងសេរីភាព មានចំនួនច្រើន និងចាត់ចូលក្នុងប្រភេទជាច្រើន ដូចជាជាសិទ្ធិកុមារ ឬ សិទ្ធិនារីជាដើម។ អ្វីទៅជាសិទ្ធិចម្បង (Fundamental/Basic Rights) នៅតែស្ថិតនៅក្នុងភាពមិនច្បាស់លាស់ ដោយសារ

---

[4] ICCPR, *supra* note 4 ។

វាអាស្រ័យទៅតាមការចែងកំណត់ក្នុងសន្ធិសញ្ញា។[5] គេអាចនិយាយបានថា សិទ្ធិចម្បងជាសិទ្ធិដាច់ខាត ដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤ របស់កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។[6] គេក៏អាចនិយាយបានថា សិទ្ធិចម្បង គឺជាសិទ្ធិដែលមានចែងក្នុង រដ្ឋធម្មនុញ្ញ ដែលមានឋានៈធម្មនុញ្ញ (Constitutional Status)[7] ដោយឈ្មោះសិទ្ធិទាំងឡាយក្នុងករណី មានទំនាស់នឹងសិទ្ធិចម្បងទាំងនេះ។ ទោះបីជាយ៉ាងនេះក្តី សិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ មិនប្រាកដថា សុទ្ធតែជាសិទ្ធិចម្បង តាមការយល់ឃើញរបស់អ្នកស្រាវជ្រាវ ឬ រដ្ឋដទៃទៀតឡើយ។

សិទ្ធិរួចផុតពីអំពើទារុណកម្ម និងសិទ្ធិសុវត្ថិភាពបុគ្គល មានទំនាក់ទំនងគ្នា។ ការឃុំខ្លួនបុគ្គលដោយអាថ៌កំបាំង អាចនាំឲ្យមានអំពើទារុណកម្ម។ សិទ្ធិទាំងពីរនេះ ពិតជាសិទ្ធិចម្បង ទទួលយកជាទូទៅដោយរដ្ឋ ក្រោមហេតុផល៖ ទីមួយ សិទ្ធិនេះ ស្ថិតនៅក្នុងប្រភេទនៃសិទ្ធិដាច់ខាត។ ទីពីរ វាជាប្រភេទសិទ្ធិបុគ្គល (Individual Rights) ដែលមានកំណើតមុនគេ មានចែងក្នុងសេចក្តីប្រកាស ស្តីពីសិទ្ធិមនុស្សរបស់ប្រទេសបារាំង ឆ្នាំ១៧៨៩។[8] ដោយសារវត្តមានជាយូរមកហើយ ទើបការហាមឃាត់អំពើទារុណកម្ម ត្រូវចាត់ថា ជាវិធានទំនៀមទម្លាប់អន្តរជាតិ[9] មានឋានៈជាវិធានខ្ពស់បំផុត (Peremptory Norm/*Jus Cogens*)។[10] តុលាការសិទ្ធិមនុស្សអឺរ៉ុប បានចាត់ទុកថា សិទ្ធិទាំងពីរនេះ ជាតម្លៃ

---

[5] សន្ធិសញ្ញាសិទ្ធិអឺរ៉ុប ដាក់ចំណងជើងសិទ្ធិចម្បង អាចត្រូវបានគេអះអាងថា សិទ្ធិទាំងនោះ ជាសិទ្ធិចម្បង, The European Convention for the Protection of Human Rights and Fundamental Freedoms, 4 November 1950, ETS 5។

[6] International Covenant on Civil and Political Rights, 16 December 1966, United Nations, Treaty Series, vol. 999, p. 171។

[7] David Sloss, the Role of Domestic Courts in Treaty Enforcement, A Comparative Study, Israel, 2009, p. 35.

[8] Declaration of the Right of Man and the Citizen, 26 August 1789, available at: http://www.refworld.org/docid/3ae6b52410.html [accessed 22 October 2018]

[9] ICTY, *Prosecutor v. Anto Furundzija*, Trial Chamber, IT-95-17/1-T, 10 December 1998, paras. 144, 154 -156; ICTY, *Prosecutor v. Dragoljub Kunarac*, Trial Chamber, IT-96-23-T & IT-96-23/1-&, 22 February 2001, para. 466.

[10] មាត្រា ៥៣ នៃអនុសញ្ញាទីក្រុងវៀនស្តីពី ច្បាប់សន្ធិសញ្ញា ឆ្នាំ១៩៦៩៖ នៅពេលអនុម័តសន្ធិសញ្ញា សន្ធិសញ្ញានឹងមោឃភាព ប្រសិនវាទំនាស់នឹង វិធានខ្ពស់បំផុតនៃច្បាប់អន្តរជាតិទូទៅ។ សម្រាប់គោលបំណងនៃសន្ធិសញ្ញានេះ

ចម្បងនៃសង្គមអឺរ៉ុប (Core Value)[11] ដែលបានទាញចេញពីទស្សនៈ បុគ្គលនិយម (Individualism[12]) សំខាន់ជាងសហាមូភាពនិយម (Collectivism)។

## ២.៣. ការបំពានសិទ្ធិ និង ដំណោះស្រាយ

ផ្នែកនេះ សូមធ្វើការបញ្ជាក់ថា មិនមែនសុទ្ធតែគ្រប់សកម្មភាពរបស់បុគ្គល ឬ អាជ្ញាធរទាំងអស់ សុទ្ធតែជាការបំពានសិទ្ធិទេ។ បុគ្គលម្នាក់ជាជនរងគ្រោះ នៃអំពើប្លន់ប្រដាប់អាវុធ ធ្វើឲ្យគាត់បាត់បង់ទ្រព្យ និង រងរបួស។ ជនល្មើស ត្រូវបានចាប់ខ្លួន ឃុំខ្លួន ចោទប្រកាន់ មានមេធាវីជួយការពារ តុលាការបានវិនិច្ឆ័យសេចក្តីដោយឆាប់រហ័ស តាមនីតិវិធីច្បាប់ ចេញសាលក្រម ដាក់ទោស ហើយ ជនរងគ្រោះទទួលបានសំណងជាក់ស្តែងពិតមែន។ ក្នុងករណីនេះ វាគ្រាន់តែជាការបំពានច្បាប់ព្រហ្មទណ្ឌតែប៉ុណ្ណោះ វាមិនមានការបំពានសិទ្ធិមនុស្សភាគីណាមួយទេ។ ផ្ទុយទៅវិញ ប្រសិនបើអាជ្ញាធរទទួលបានបណ្តឹងហើយ មិនបានចាត់វិធានការដោយ អូសបន្លាយពេលវេលាយូរ ដោយគ្មានមូលហេតុសមស្រប បញ្ហាបំពានសិទ្ធិនឹងកើតជារូបរាង។ ដូចគ្នាដែរ ប្រសិនបើជនត្រូវចោទ ត្រូវបានចាប់ខ្លួនហើយទទួលរងទារុណកម្ម ដោយមន្ត្រីនគរបាល តុលាការវិនិច្ឆ័យសេចក្តី ធ្វើការកាត់ទោស ដោយផ្អែកតាមចម្លើយសារភាពបានតាមរយៈអំពើទារុណកម្ម តែមួយមុខនោះ ទើបអាចជាការបំពានលើសិទ្ធិទទួលបានការវិនិច្ឆ័យសេចក្តីដោយយុត្តិធម៌ ឬ ការមិនមានសំណងពីមន្ត្រីប៉ូលីស ឬ គ្មានការដាក់ទណ្ឌ

---

វិធានខ្ពស់នៃច្បាប់អន្តរជាតិទូទៅ ជាវិធានដែលទទួលស្គាល់ និងទទួលយក ដោយសហគមន៍រដ្ឋទាំងមូល ថាជាវិធានដែលមិនត្រូវបានផ្អាកការគោរព និង អាចកែប្រែបានដោយ វិធាននៃច្បាប់អន្តរជាតិទូទៅ ដែលមានចរិតដូចគ្នាតែប៉ុណ្ណោះ, សូមមើល Vienna Convention on the Law of Treaties, 23 May 1969, United Nations, Treaty Series, vol. 1155, p. 331។ Erika de Wet, *the Prohibition of Torture as an International Norm of Jus Cogens and Its Implications for National and Customary Law*, 15 EJIL ( 2004), pp. 97-121.

11 សហាគមន៍អឺរ៉ុប, A Guide to the Implementation of Article 3 of the European Convention on Human Rights, Human Rights Handbooks, No. 6, 2002, ទំ.៨។ In case of claiming for compensation for violations of fundamental rights, Hon Mr. Justice Mukul Mudgal, Prisons and Custody: Application of International Human Rights Norms by the Supreme Court of India, Developing Human Rights Jurisprudence, Vol. 8, 2001, p.135.

12 Josiah A.M. Cobbah, *African Values and Human Rights Debate: An African Perspective*, 9 Human Rights Quarterly 309-331, 1987.

កម្មដល់មន្ត្រីនគរបាល ដែលបានធ្វើអំពើទារុណកម្ម នេះអាចជាការបំពាននូវសិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។ វាក៏នឹងអាចបំពាននូវមាត្រាខាងក្រោមផងដែរ។

មាត្រា ២ កថាខណ្ឌទី៣ ចំណុច ក នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា រដ្ឋភាគីនៃកាតិកាសញ្ញានេះ សន្យាធានាថា៖ *"ជនណាដែលត្រូវបានគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួន ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិឲ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ ទោះបីការរំលោភនោះបាន ប្រព្រឹត្តដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ"*។ រីឯចំណុច ខ វិញបានធានាថា៖ *"ជនណាដែលប្តឹងឲ្យមានការដោះស្រាយបែបនេះ ត្រូវមានសិទ្ធិឲ្យអាជ្ញាធរ មានសមត្ថកច្ចិខាងយុត្តិធម៌ ខាងរដ្ឋបាល ឬ ខាងនីតិបញ្ញត្តិ ឬ អាជ្ញាធរមានសមត្ថកិច្ចដទៃទៀត សម្រេចឲ្យខ្លួន ដោយយោងតាមច្បាប់របស់រដ្ឋនោះ និងត្រូវបង្កើតលទ្ធភាពនៃការប្តឹងទៅតុលាការផង"*។[13]

មាត្រាទាំងពីរខាងលើនេះ ពាក់ព័ន្ធនឹងការធ្វើបណ្តឹង និង ការដោះស្រាយបណ្តឹងចោទប្រកាន់លើការបំពានសិទ្ធិមនុស្ស ដើម្បីផ្តល់នូវដំណោះស្រាយឲ្យមានប្រសិទ្ធភាព និង អាចអនុវត្តបាន (Effective and Enforceable Remedy)។[14] នេះមានន័យថា ជនរងគ្រោះ នឹងទទួលបានសំណងនៃអំពើបំពានសិទ្ធិ ហើយសំណងនេះ ត្រូវបានផ្តល់ជាក់ស្តែង និងពិតប្រាកដមែនដល់ជនរងគ្រោះ។ តុលាការសិទ្ធិមនុស្សអឺរ៉ុប បាននិយាយច្បាស់ថា ការការពារសិទ្ធិសេរីភាព ត្រូវតែជាក់ស្តែង មិនមែននៅលើតែក្រដាសទេ (Protection of Rights Is Not Just Illusory)។[15] វាក៏អាចពាក់ព័ន្ធជាមួយនឹងសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ ដែលមានសមាសធាតុផ្សំចំបងជាច្រើន ដូចជា សម

---

[13] ICCPR, supra note 4។.

[14] Id., Article 2(3)(a)-(c)។

[15] *Airey v. Ireland,* App. no. 6289/73, judgment of 9 October 1979, para. 24.

ភាពស្មើភាគីក្នុងការប្រឆាំង (Equality of Arms)។[16] ការវិនិច្ឆ័យសេចក្តីថាសិទ្ធិប្រភេទនេះ ត្រូវបានបំពាន ត្រូវពិនិត្យនីតិវិធី ឬដំណើរការនៃសំណុំរឿងទាំងស្រុង និងតាមករណីនីមួយៗ។[17]

## ២.៤. ការការពារសិទ្ធិ តាមយន្តការតុលាការ

**<u>២.៤.១. សមត្ថកិច្ច និង ការបកស្រាយ (Judicial Creation):</u>** ក្នុងការពិចារណានូវ ពាក្យបណ្តឹងសិទ្ធិមនុស្ស មានសំណួរសួរថាតើតុលាការប្រភេទ និងកម្រិតណា ដែលមានសមត្ថកិច្ច ក្នុងការពិនិត្យបណ្តឹង សិទ្ធិមនុស្ស។ វាអាស្រ័យទៅតាមច្បាប់។ ប្រទេសកាណាដា បានបង្កើតតុលាការជាក់លាក់មួយទទួល មើលបណ្តឹងសិទ្ធិមនុស្សពាក់ព័ន្ធនឹងការរើសអើង។[18] ប្រទេសខ្លះ បានត្រឹមតែបង្កើតអង្គវិនិច្ឆ័យបញ្ហាសិទ្ធិមនុស្ស ក្នុងប្រព័ន្ធតុលាការដែលមានស្រាប់។[19] ប្រទេសខ្លះ តុលាការកម្រិតណាក៏មានសមត្ថកិច្ចពិនិត្យបណ្តឹងសិទ្ធិមនុស្សដែរ។ ដោយឡែកប្រទេស ឥណ្ឌា ទំនងជាផ្តល់សមត្ថកិច្ចដល់តុលាការជាន់ខ្ពស់ (High/Appellate Court) ឬ តុលាការកំពូលតែប៉ុណ្ណោះ។[20]

សំណួរជាច្រើន បានចោទសួរនៅចំពោះមុខតុលាការ ថាតើសិទ្ធិ ដែលត្រូវបានចោទថាបានបំពាន មិនត្រូវបានដាក់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញ ឬ ច្បាប់ពាក់ព័ន្ធជាមុន បុគ្គលរងការបំពាន អាចលើកសិទ្ធិនោះមកសំអាងក្នុងរឿងក្តីរបស់ខ្លួនបានឬទេ?។ តុលាការសិទ្ធិមនុស្សទ្វីបអាហ្វ្រិក បានអះអាងថា ទោះបីសិទ្ធិប្តឹងឧទ្ធរណ៍មិនមានចែងក្នុងច្បាប់ជាតិ ក៏ភាគីក្នុងរឿងក្តីនោះ មានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍បានដែរ ដោយបណ្តឹងឧប្រាស្រ័យនេះ មានចែងក្នុងសន្ធិសញ្ញា ដែលរដ្ឋជាភាគី ហើយសន្ធិសញ្ញា ជាផ្នែកមួយនៃច្បាប់ជាតិ។ ដូចនេះ បុគ្គលនោះ មានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងឧទ្ធ

---

[16] Stefan Treschsel, Human Rights in Criminal Proceedings, 2006, p.94.

[17] *Allan v. the United Kingdom* [2002] ECHR 702, para.42, ODIHR, Legal Digest of International Fair Trial Rights, Section 6.1.2 (Equality in Presenting one's Case: The Adversarial Nature of Proceedings), 2012, p.112.

[18] តុលាការសិទ្ធិមនុស្សត្រូវបានបង្កើតឡើងតាមច្បាប់ Human Rights Acts, R.S.C., 1985, ផ្នែក ៤៨(១)។

[19] Human Rights Chamber for Bosnia and Herzegovina, http://www.hrc.ba/ENGLISH/members_new.htm

[20] Anne Bayefsky & Joan Fitzpatrick, *International Human Rights Law in United States Courts: A Comparative Perspective*, 14 Mich. J. Int'lL. 1 (1992). Available at: http://repository.law.umich.edu/mjil/vol14/iss1/1, pp. 83-84. In case of claiming for compensation for violations of fundamental rights, Hon Mr. Justice Mukul Mudgal, Prisons and Custody, *supra* note 11, p.137.

រណ៍ តាមសន្និសញ្ញា ដែលរដ្ឋជាភាគី។[21] ស្រដៀងគ្នានេះដែរ តុលាការអាចប្រឈមនឹងបញ្ហាច្បាប់ថា តើដាក់ឲ្យរដ្ឋ ឬ អាជ្ញាធររបស់រដ្ឋទទួលខុសត្រូវក្នុងការបំពានសិទ្ធិមនុស្សក្នុងទម្រង់អ្វី ហើយចាំបាច់ទេ បន្ថែមពីការទទួលខុសត្រូវក្នុងច្បាប់ព្រហ្មទណ្ឌ និង ការទទួលខុសត្រូវរដ្ឋប្បវេណី ?

ជាការឆ្លើយតប តុលាការកំពូលប្រទេសឥណ្ឌា បានបកស្រាយបែបឆ្នៃប្រឌិត (Judicial Creation) ថា៖ *"យើងត្រូវបង្កើតនូវច្បាប់របស់យើង ប្រសិនបើរកឃើញថា មានភាពចាំបាច់ក្នុងការបង្កើតនូវគោលការណ៍ទទួលខុសត្រូវថ្មី* (New Principle of Liability) *ដើម្បីដោះស្រាយស្ថានភាពមិនធម្មតា ដែលបានកើតហើយ ឬ ដែលនឹងទំនងជាកើតមាននាពេលអនាគត" ។*[22] វាជាការទទួលខុសត្រូវក្នុងវិស័យច្បាប់សាធារណៈ (Public Law) ឬក្នុងវិស័យរដ្ឋបាល ដែលអាជ្ញាធរ ឬ រដ្ឋ បានធ្វើសកម្មភាព ប៉ះពាល់ដល់សិទ្ធិសេរីភាពបុគ្គល ដែលត្រូវទទួលខុសដោយការផ្តល់ជាសំណងព្យសនកម្ម ។ វាអាចជាទម្រង់ទទួលខុសត្រូវតឹងរឹង (Strict Liability)ផងដែរ។[23]

**<u>២.៤.២. សិទ្ធិចម្បង និងការអន្តរាគម</u>**៖ តុលាការនឹងអន្តរាគមន៍ចំពោះការបំពានសិទ្ធិសេរីភាពចម្បងធ្ងន់ធ្ងរ។ ឧទាហរណ៍ករណីក្នុងប្រទេសខ្លះ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ បានឃុំឃាំងបុគ្គលខុសច្បាប់ក្នុងរយៈពេលយូរ ហើយធ្វើទារុណកម្មធ្ងន់ធ្ងរ តុលាការបានរកឃើញថា សកម្មភាពនោះវាជាការបំពានធ្ងន់ធ្ងរ។ តុលាការបានតម្រូវឲ្យ មន្ត្រីនគរបាលនោះ ទទួលខុសត្រូវសងនូវសំណងព្យសនកម្មដល់ជនរងគ្រោះនៃការបំពានសិទ្ធិនោះ។

> *[...] មន្ត្រីនគរបាលបំពានច្បាប់ ក្នុងអំឡុងពេលប្រតិបត្តិការការងារ របស់ខ្លួន...រដ្ឋបានខកខានបំពេញកាតព្វកិច្ចខ្លួនក្នុងការបង្រៀន និង បណ្តុះបណ្តាលមន្ត្រីនគរបាល ស្តីពី*

---

[21] Constitutional Court of Uganda, *Karugaba v. Attorney General*, 05 February 2009, ILDC 1284 (UG 2009), Holding para. 6.

[22] *Union Carbide Corporation and Others v. Union of India and Others*, cited in Hon Mr. Justice Mukul Mudgal, Prisons and Custody, *supra* note 11, p. 141.

[23] *Nilabati Beherav Stateof Orissa*, [1993] 2 SCR 581.

*វិធីសាស្ត្រការងារប៉ូលីសមស្រប និងទទួលយកបាន...ដូចនេះ វាជាការសមស្រប ដែលរដ្ឋត្រូវទទួលខុសត្រូវចំពោះអំពើបំពានរបស់មន្ត្រីនគរបាល...។*[24]

ក្នុងករណីខ្លះ តុលាការបានចេញសេចក្តីសម្រេច ឲ្យរដ្ឋសងលុយដល់ជនរងគ្រោះ នៃអំពើរបស់អាជ្ញាធររបស់ខ្លួន ជាស្ថាប័នរបស់ខ្លួន ដោយសារកំហុសនៃការមិនបានជ្រើសរើសមន្ត្រីមិនបានល្អ ឬ ការមិនបានបណ្តុះបណ្តាលណែនាំមន្ត្រីឲ្យគោរពច្បាប់បានល្អ។[25] រដ្ឋ ក៏មានសិទ្ធិទាមទារនូវប្រាក់សំណងពីមន្ត្រីទាំងនោះមកវិញបានដែរ។[26] មូលហេតុនៃការទទួលខុសត្រូវ ក៏ដោយសាររដ្ឋ ឬ អាជ្ញាធរ មិនបានយកចិត្តទុកដាក់បង្ការការបំពានសិទ្ធិ (Lack of Due Diligence)[27]។ ជួលកាល សំណងអាចជាសំណងមនុស្សធម៌ (Exemplary Compensation) ដែលជាចំនួនទឹកប្រាក់សរុបផ្តល់ដល់ជនរងគ្រោះ។[28]

ការជួសជុល ការខូចខាត (Reparation) ដោយសារការបំពានសិទ្ធិ អាចជាការគ្រាន់តែប្រកាសថា អាជ្ញាធរបានបំពានសិទ្ធិ (Declaratory Judgment)[29] ឬ ថាបទប្បញ្ញត្តិនៃច្បាប់ជាតិ មិនស្របនឹងសន្ធិសញ្ញាសិទ្ធិមនុស្ស (Declaration of Incompatibility) ដើម្បីឲ្យសភាធ្វើវិសោធនកម្មច្បាប់

---

[24] National Court of Justice of Papua New Guinea, *Lamon v. Bumai*, [2010] PGNC 21, 12 March 2010, printed in 4 Pacific Human Rights Law Digest, 2013, p.1.

[25] *Id*., p.3.

[26] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០១១ មាត្រា ៧៤៩ (ដកស្រង់ទាំងស្រុងក្នុងលេខយោងទី ៣៨ ខាងក្រោម)។

[27] The Obligation to act with the necessary due diligence to protect individual rights from human rights violations committed by private actors, *see* IACHR, Simone André Diniz v. Brazil. Case No. 12.001. Merits. Report No. 66/06, October 21, 2006, para. 101; IACHR, Jessica Lenahan (Gonzáles) et al. v. United States. Case No. 12.626. Merits. Report No. 80/11, July 21, 2011; para. 130Osman ECHR

[28] *Aggravated damages in contrast to exemplary damages are compensatory in nature, being awarded for injury to the plaintiff s feelings caused by insult, humiliation and the like Exemplary damages on the other hand, go beyond compensation and are awarded as punishment to the guilty to deter from any such proceeding for the future and as a proof of the detestation of the jury to the action itself*, see *Lamb v Cotogno* (1987) 164 CIR 1 at 8.

[29] Golder v. UK [Plenary] App No 4451/70 Judgment from 21.02.1975 §46; see as well, Ivan Dimitrijevic, Remedies for Human Rights Violations in Jurisprudence of the European Court of Human Rights and Their Execution by Member States, Thesis, 2017, p. 13.

ទាន់ពេលវេលា ឲ្យស្រូបនឹងសន្ធិសញ្ញា។[30] ជាចុងក្រោយ វាអាចជាការបន្ថយទោស ជាថ្នូរនឹងការបំពានសិទ្ធិរបស់បុគ្គល។

> *"ក្នុងករណី ដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធភាព អង្គជំនុំជម្រះ យល់ឃើញថា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ដែល អង្គជំនុំជម្រះនឹងត្រូវយកមកសម្រេចនៅដំណាក់កាល សម្រេចអំពីទោស រយៈពេលដែលគាត់ ជាប់ឃុំឃាំង ដោយខុសច្បាប់នៅតុលាការយោធា ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ និងថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧។*[31]

អាជ្ញាធររដ្ឋ ឬអ្នកសិក្សាស្រាវជ្រាវខ្លះ បានជំទាស់នឹងការដាក់ឲ្យរដ្ឋទទួលខុសត្រូវចំពោះអំពើបំពានសិទ្ធិចម្បង។ តាំងពីបុរាណ រដ្ឋនឹងមិនទទួលខុសត្រូវក្រៅកិច្ចសន្យាចំពោះទង្វើខុសឆ្គងលើប្រជាពលរដ្ឋទេ។ រដ្ឋមានអភ័យឯកសិទ្ធិដាច់ខាត (Absolute Immunity) រួចពីបណ្តឹងទាមទារសំណងស៊ីវិលពីព្រោះការបំពានសិទ្ធិស្ថិតនៅក្នុងវិស័យច្បាប់ឯកជន។[32]

<u>**២.៤.៣. កំណត់សំគាល់៖ **</u>រដ្ឋបានចំណាយធនធានមនុស្ស ថវិកា ដើម្បីផ្តល់សច្ចាប័នដល់សន្ធិសញ្ញាសិទ្ធិមនុស្សដោយស្ម័គ្រចិត្ត។ ក្រៅពីបំណងធានាសិទ្ធិប្រជាពលរដ្ឋ រដ្ឋប្រកាសប្រាប់អន្តរជាតិថាខ្លួន ជាសមាជិកសន្ធិសញ្ញា និងសន្យាគោរពតាម។ ក្នុងករណីខ្លះ រដ្ឋមិនបានរារាំងមិនឲ្យបំពានសិទ្ធិថែមទាំងអាជ្ញាធររបស់ខ្លួនបានបំពានសិទ្ធិបុគ្គលចម្បង ថែងក្នុងរដ្ឋធម្មនុញ្ញដោយផ្ទាល់ថែមទៀត។

---

[30] Declarations of Incompatibility under the Human Rights Act 1998, see Table compiled on the basis of the Ministry of Justice report Responding to Human Rights Judgments: Report to the Joint Committee on Human Rights on the Government response to human rights judgments 2011-12, September 2012 available at http://www.justice.gov.uk/downloads/publications/policy/moj/responding-human-rightsjudgments.pdf <Accessed 30 April 2013>.

[31] Trial Chamber of ECCC, Decision on Request for Release (public), E39/5, 15 June 2009, para.36.

[32] *Nilabati Beherav Stateof Orissa*, [1993] 2 SCR 598-600.

រដ្ឋបានធ្វើច្បាប់ជាតិ សរសេរបញ្ចូលនូវសិទ្ធិមួយចំនួនចូល តែមិនបានទាំងអស់ទេ។ នេះជារឿងពិតទូទៅ ដែលជៀសមិនរួចសម្រាប់គ្រប់រដ្ឋទាំងអស់។ ក្នុងន័យនេះ ការអះអាងថា សិទ្ធិណាមួយមិនបាននិយាយក្នុងច្បាប់ជាតិ ហើយមិនអនុញ្ញាតឲ្យបុគ្គលប្រាស្រ័យសិទ្ធិទាំងនោះ វានឹងមិនសមហេតុផលទាល់តែសោះ។ វានឹងមិនស្របនឹងមាត្រា ២៦ ដែលទាមទារឲ្យអនុវត្តសន្ធិសញ្ញាដោយសុទ្ធចិត្ត។[33]

ការអះអាងថា រដ្ឋ ឬ អាជ្ញាធររបស់ខ្លួន មានអភ័យឯកសិទ្ធិរួចពីការទាមទារសំណងស៊ីវិល លែងមានមូលដ្ឋានរឹងមាំទៀតហើយ។ បើទោះបីជាមិនមានច្បាប់ចែងច្បាស់ថា រដ្ឋត្រូវសងសំណងដល់ជនរងគ្រោះនៃអំពើបំពានសិទ្ធិដោយអាជ្ញាធររបស់ខ្លួន តែមានមាត្រាច្បាប់ជាច្រើនចែងដោយប្រយោល ក្នុងការទទួលខុសត្រូវក្រៅកិច្ចសន្យា[34] ក្នុងរដ្ឋធម្មនុញ្ញ។[35] សាលក្រមអន្តរជាតិ ឬ ជាតិក៏បានបញ្ជាក់បញ្ហានេះដែរ ដូចបានបង្ហាញខាងលើ។

វាជាការទទួលខុសត្រូវមួយ ចំពោះការរំលោភសិទ្ធិចម្បង ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ជាច្បាប់កំពូល ដែលទាំងអស់គ្នាអះអាងថាដាច់ខាតត្រូវតែធានា និងគោរព (Constitutionalism)។ ការទទួលខុសត្រូវប្រភេទនេះ ខុសពីការទទួលខុសត្រូវព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ដែលបង្កដោយអំពើ

---

[33] Vienna Convention on the Law of Treaties, *supra* note 10។

[34] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០១១ មាត្រា ៧៤៩៖ ១. បើមន្ត្រីរាជការដែលទទួលការអនុវត្តអំណាចសាធារណៈរបស់រដ្ឋ ឬស្ថាប័នសាធារណៈ បានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះ រដ្ឋ ឬស្ថាប័នសាធារណៈ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ។ ២. ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ បើកម្រិតនៃការបំពាន ករណីកិច្ចរបស់មន្ត្រីរាជការ ក្នុងការជៀសវាងនូវលទ្ធផល មានភាពធ្ងន់ធ្ងរ រដ្ឋ ឬស្ថាប័នសាធារណៈ អាចទាមទារសំណងពីមន្ត្រីរាជការនោះបាន។

[35] មាត្រា៣៩ នៃធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ៖ ប្រជាពលរដ្ឋមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋរបស់សង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។

ព្រហ្មទណ្ឌ ដែលរំលោភច្បាប់ព្រហ្មទណ្ឌ។ វាជាការទទួលខុសត្រូវបំពេញបន្ថែមក្នុងករណីបំពានសិទ្ធិ ចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ ឬបំពានច្បាប់ធម្មនុញ្ញផងដែរ។

ការដាក់ការទទួលខុសត្រូវនេះ គឺដើម្បីការពារធម្មនុញ្ញ ដើម្បីឲ្យការទទួលខុសត្រូវទាំងអស់ មានលក្ខណៈពេញលេញ ធ្វើឲ្យមន្ត្រីរាងចាល នឹងមិនបំពានសិទ្ធិបុគ្គល នាំឲ្យមានយុត្តិធម៌សង្គម។ រដ្ឋ នឹងមិនខាតទេ។ ទោះបីជាក្នុងករណីខ្លះ រដ្ឋចេញលុយសងសំណង រដ្ឋអាចទាមទារពីមន្ត្រីបំពាននោះ វិញបាន។[36] ការណ៍ដែលតុលាការដាក់ការទទួលខុសត្រូវលើរដ្ឋ នឹងជួយឲ្យមន្ត្រីខិតខំអនុវត្ត និងគោរព តាមច្បាប់ ជាគម្រូដល់ប្រជាពលរដ្ឋ ហើយក៏នាំឲ្យរដ្ឋត្រូវបណ្តុះបណ្តាល និងជ្រើសរើសមន្ត្រីដោយ ប្រយ័ត្នប្រយែង ទទួលបានមន្ត្រីមានគុណធម៌ មានសមត្ថភាព។ ប្រសិនបើមិនដូចនេះទេ រដ្ឋនឹងខាត ថវិកាជាតិ ជាមួយនឹងនេះ នឹងអាប់អោនកិត្តិយស ដោយសារមន្ត្រីមួយចំនួនណាមួយ ដែលបំពាន អំណាច ឬរំលោភសិទ្ធិប្រជាពលរដ្ឋ។

តុលាការសម្រេចដាក់ការទទួលខុសត្រូវលើរដ្ឋ ឬអាជ្ញាធររបស់រដ្ឋយ៉ាងនេះ ធ្វើឡើងក្នុងដែន សមត្ថកិច្ច ក្នុងក្របខណ្ឌច្បាប់ ចូលរួមធានាការគោរពសន្ធិសញ្ញាសិទ្ធិមនុស្ស ដែលរដ្ឋជាភាគី និងលើក កម្ពស់ការការពារ គោរព និងផ្តល់តម្លៃដល់ច្បាប់រដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល។ វាក៏បានអនុលោម ផងដែរ ដល់គោលការណ៍អព្យាក្រឹត្យភាព ឯករាជភាព និងកិត្យានុភាពរបស់អង្គតុលាការ ដែលជា អំណាចឯករាជ្យមួយផងដែរ។

## ៣. សន្ទេប

ខ្លឹមសារខាងលើ បានបង្ហាញថា អង្គតុលាការ ដែលជាស្ថាប័នឯករាជ្យមួយនៃរដ្ឋ ដែលមាន តួនាទី ក្នុងការគោរពកាតព្វកិច្ចក្នុងសន្ធិសញ្ញា ដែលរដ្ឋជាភាគី។ តុលាការ បានដើរតួនាទីចម្បង និងចុង ក្រោយ ក្នុងការធានាការគោរពនូវសិទ្ធិមនុស្ស។ មាននិន្នាការ ដែលតុលាការ បានដាក់ឲ្យរដ្ឋទទួលខុស

[36] មាត្រា ៧៤៩ នៃក្រមរដ្ឋប្បវេណីកម្ពុជា, លេខ យោងទី៣៥ ខាងលើ។

ត្រូវ តាមរយៈការសម្រេចឲ្យអាជ្ញាធរ ផ្តល់សំណងដល់ជនរងគ្រោះ ចំពោះការបំពានសិទ្ធិមនុស្ស ជាពិសេស សិទ្ធិចម្បងដូចជា សិទ្ធិរួចផុតពីអំពើទារុណកម្មជាដើម។ វាជាប្រភេទនៃការទទួលខុសត្រូវផ្សេងពីការទទួលខុសត្រូវព្រហ្មទណ្ឌ ឬ ក្រៅកិច្ចសន្យា ហើយដែលចាំបាច់ ដើម្បី ធ្វើឲ្យអាជ្ញាធរ ដែលត្រូវបានតែងតាំង ជាអ្នកផ្តល់សេវាកម្មជូនប្រជាពលរដ្ឋ មិនត្រូវបំពានសិទ្ធិរបស់ម្ចាស់អំណាច។